# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១១៧/០១៧/២០០៦

ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**សេចក្តីសម្រេច**

លេខ : ០៨៣/០១០/២០០៦ កបធ.ច

ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រ
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់ឯកឧត្តម **គង់ គាំ** ប្រធានគណបក្សសម រង្ស៊ី ស្តីទី ផ្ទេរសិទ្ធិជូនលោក **ខាង់ ឃុនសារិន** ជាសមាជិកគណៈកម្មាធិការបោះឆ្នោតគណបក្សសម រង្ស៊ី ដើម្បីជាតំណាងដាក់ពាក្យបណ្តឹង និង សវនាការនៅក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញពាក្យបណ្តឹងរបស់លោក **ថាច់ ឃុនសារិន** ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ប្តឹងទាមទារសុំឱ្យលុបឈ្មោះចំនួន០៨នាក់ នៅសង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ចេញពីបញ្ជីបោះឆ្នោត ដែលអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ១១:១០នាទី
- បានឃើញលិខិតឧទ្ទេសនាមលេខ ៩១៤/០៦ គ.ជ.ប ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ ចាត់តាំងតំណាង **គ.ជ.ប** ឱ្យចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ សម្រេចបដិសេធពាក្យបណ្តឹងលេខ ០០១១/០៦ ក.ទ.ជ.ប ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់លោក **ថាច់ ឃុនសារិន**
- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០០៦ នៅសង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ១៤:៣០ នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សាក្សី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងរបស់លោក **ថាច់ ឃុនសារិន** ជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលបិទផ្សាយជាសាធារណៈបញ្ជីបោះឆ្នោតដំបូង ។ ដូច្នេះយោងតាមមាត្រា ៤២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាត្រា ៦៤ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង មាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងនេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះនិងក្នុងពាក្យបណ្តឹង លោក **ថាច់ ឃុនសារិន** បានបញ្ជាក់ថា ដោយសារគាត់ជាចៅសង្កាត់រង សង្កាត់ច្បារអំពៅទី១ គាត់ស្គាល់ប្រជាពលរដ្ឋទាំង ០៨រូបច្បាស់ ហើយគាត់បានរស់នៅក្នុងសង្កាត់នេះ ១០ឆ្នាំហើយ ។ ឯសាក្សីឈ្មោះ ឈួន ទី ទីលំនៅសង្កាត់ដដែល បានបញ្ជាក់ថា អ្នកទាំង ០៨រូប និយាយភាសាវៀតណាម មើលទូរទស្សន៍វៀតណាម សំលៀកបំពាក់វៀតណាម និង ទំនៀមទម្លាប់តាមវៀតណាម ហើយថាអ្នកទាំងនោះគ្មានអត្តសញ្ញាណប័ណ្ណទេ

- យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ និង ក្នុងពេលឆ្លើយបំភ្លឺ ឯកឧត្តម **មាន សុផឹ** និង ឯកឧត្តម **ម៉ៅ សុភារិទ្ធ** សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយថា " *នៅក្នុងសវនាការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លោក ថាច់ ឃុនសារិន គ្មានភស្តុតាងឯកសារមកបង្ហាញក្រៅពីសំអាងទៅលើឈ្មោះជាវៀតណាមនិងសំនៀងជាវៀតណាម។ លោក ថាច់ ឃុនសារិន បានអះអាងថា ខ្លួនជាអ្នកប្តឹងផង និង ជាអ្នកចូលរួមដោះស្រាយផង ហើយបានចុះហត្ថលេខាក្នុងការដោះស្រាយនៅក្នុងក្រុមប្រឹក្សាឃុំសង្កាត់ច្បារអំពៅទី១ ដោយទទួលស្គាល់ថា ០៣ នាក់ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិ ខ្មែរ និង ០៥ នាក់មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ* "។ ទន្ទឹមនឹងនេះ ឯកឧត្តម **មាន សុផឹ** សមាជិកគ.ជ.ប បានបញ្ជាក់ថា " *លោក ថាច់ ឃុនសារិន មិនស្គាល់ពីអត្តសញ្ញាណ និង ទីកន្លែងរស់នៅរបស់ជនទាំង ០៨ នាក់ នេះទេ* "
- យល់ឃើញថា លោក **ថាច់ ឃុនសារិន** សំអាងថា ពលរដ្ឋ ០៨រូប គ្មានសញ្ជាតិជាខ្មែរ ដោយគ្រាន់តែគេនិយាយភាសាវៀតណាម មើលទូរទស្សន៍ប៉ុស្តិ៍វៀតណាម ស្លៀកពាក់តាមបែបវៀតណាម ហើយបង្រៀនកូនចៅរបៀបគោរពគឺឱបដៃ និង ឱនក្បាល ។ ការសំអាងនេះ មិនមែនជាភស្តុតាងដែលអាចឱ្យក្រុមប្រឹក្សាធម្មនុញ្ញលុបឈ្មោះពីបញ្ជីបោះឆ្នោតបានឡើយ
- យល់ឃើញថា តាមការស្រាវជ្រាវដល់មូលដ្ឋានបានបញ្ជាក់ថា ក្នុងចំណោមពលរដ្ឋ ០៨រូប ដែលត្រូវបានសុំលុបឈ្មោះ ០៣រូប មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយ ០៥រូបទៀត មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ
- យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ

## សម្រេច

### ចំពោះមុខគូភាគី

**មាត្រា ១.** ទទួលពាក្យបណ្តឹងរបស់លោក **ថាច់ ឃុនសារិន** ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ ដែលសម្រេចបដិសេធបណ្តឹងលេខ ០០១១/០៦ គ.ទ.ជ.ប ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៦ ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ប៊ិន ឈិន